# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីបិទ កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី ២
## ក្រោមប្រធានបទ «ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងភាន់តែរឹងមាំ ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន»

*រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២, វេលាម៉ោង ១៤:៣០ ដល់ ១៧:០០*

*(រយៈពេល ៥ នាទី)*

- *ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ាន និងប្រទេសដៃគូ;*
- *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ **ឯកឧត្តម, លោកជំទាវ** ថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ាន និងប្រទេសជាដៃគូ ដែលបានថ្លែងបទអន្តរាគមន៍ និង សុន្ទរកថាដ៏មានអត្ថន័យ ដែលបានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្ត និង ឆន្ទៈដ៏មុតមាំ ក្នុងដំណើរឆ្ពោះទៅមុខជាមួយគ្នាក្នុងការបំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន ស្របតាមប្រធានបទរបស់យើង ក្នុងថ្ងៃនេះ ។

ការទទួលស្គាល់ភាពចាំបាច់ នៃការពង្រឹងសហគ្រិនភាព និងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី គឺជាការបោះជំហានទៅមុខយ៉ាងសំខាន់ ។ ក្នុងស្មារតីនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្ស និងមានកម្លាំងចិត្ត ប្រកបដោយសុទិដ្ឋិនិយម ដោយបានសង្កេតឃើញថា យើងមានទស្សនៈវិស័យដូចគ្នា និងមានជំហររួមគ្នា ក្នុងការបន្តលើកកម្ពស់សមភាពយេនឌ័រ, ការផ្តល់សិទ្ធិអំណាច និង ការគាំទ្រដល់ស្ត្រី ដែលជាគុណតម្លៃដ៏វិសេស-វិសាល សម្រាប់ការអភិវឌ្ឍសហគមន៍អាស៊ានទាំងមូល ជាពិសេសក្នុងបរិការណ៍នៃការស្តារសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញ ប្រកបដោយចីរភាព បរិយាបន្ន និង ភាពរឹងមាំ ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ ។

– *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ដោយស្ត្រី គឺជាស្នូលនៃគ្រួសារ និង សហគមន៍, **«បើស្ត្រីរឹងមាំ, គ្រួសារ និងសហគមន៍អាស៊ាន របស់យើង ក៏រឹងមាំដូចគ្នាដែរ»** ។ ក្នុងន័យនេះ, ការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី គឺជាកិច្ចការមួយដ៏សំខាន់ ដែលអាចផ្តល់ និង បង្កើនឱកាសដល់ស្ត្រីក្នុងការចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ជីវភាពរបស់ខ្លួន និង គ្រួសារ ក៏ដូចជាការចូលរួមក្នុងការអភិវឌ្ឍ និងការធ្វើសមាហរណកម្មសង្គម-សេដ្ឋកិច្ចអាស៊ាន របស់យើងឱ្យកាន់តែមានភាពប្រសើរឡើង ។

ដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ចបានយ៉ាងពេញលេញ និងទូលំទូលាយ, ការពង្រឹងសមត្ថភាព និងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី គឺជាកត្តាចាំបាច់ និង មិនអាចខ្វះបាន ។ ក្នុងន័យនេះ, រដ្ឋាភិបាលនៃបណ្តាប្រទេសអាស៊ានទាំងអស់ មានកាតព្វកិច្ចធានាឱ្យបាននូវសមភាពសម្រាប់ស្ត្រី ក្នុងការទទួលបានការអប់រំ, ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, ភាពជាម្ចាស់លើការគ្រប់គ្រងធនធានហិរញ្ញវត្ថុ, សិទ្ធិចូលរួមក្នុងការសម្រេចចិត្ត និង ភាពជាអ្នកដឹកនាំ ដើម្បីឱ្យស្ត្រីគ្រប់រូបមានឱកាសពេញលេញ ទាំងក្នុងទិដ្ឋភាពសង្គម-សេដ្ឋកិច្ច, ពាណិជ្ជកម្ម និង ទិដ្ឋភាពនយោបាយ ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា **កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី ២** នាថ្ងៃនេះ នឹងបន្តក្លាយជាវេទិកាសម្រាប់ការបំផុស និង ជំរុញទឹកចិត្តដល់ស្ត្រី នៅក្នុងតំបន់អាស៊ាន ។ ខ្ញុំសូមលើកទឹកចិត្តឱ្យអាស៊ានបន្តរៀបចំកិច្ចប្រជុំកំពូលនេះ នៅឆ្នាំបន្តបន្ទាប់ទៀត ដើម្បីជាសក្ខីភាពនៃការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនៃបណ្តាប្រទេសអាស៊ាន នៅក្នុងបុព្វហេតុនៃការសម្រេចឱ្យបាននូវសមភាពយេនឌ័រនៅក្នុងប្រទេស និង ក្នុងតំបន់ ។ ជាពិសេស, ខ្ញុំមានជំនឿយ៉ាងមុតមាំថា សេចក្តីថ្លែងការណ៍ ស្តីពី **«ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និង កាន់តែរឹងមាំ៖ ការបំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន»** ដែលយើងបានពិភាក្សានាថ្ងៃនេះ នឹងទទួលបានការគាំទ្រ និង ការអនុម័តលើ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៤០ និងទី ៤១ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ខាងមុខ ។

ជាកិច្ចបញ្ចប់, ខ្ញុំសូមជូនពរឱ្យ **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់** ជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការ គឺ **អាយុ, វណ្ណៈ, សុខៈ** និង **ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបិទ **កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី ២** ចាប់ពីពេលនេះតទៅ ៕

*សូមអរគុណ!*